**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១២៤៩ សហវ.ទក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម**

**កម្មវត្ថុ:** ករណីស្នើសុំគោលការណ៍ថវិកាចំនួន ៤០៧.៩៤៨.00 ដុល្លារអាមេរិក សម្រាប់ការបោសសម្អាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ជំហានទី ២ នៅការដ្ឋានគម្រោងអភិវឌ្ឍន៍ធនធានទឹកព្រែកស្ទឹងកែវ ខេត្តកំពត។

**យោង:** លិខិតលេខ ៣៤៤ ធទឧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹក និងឧតុនិយម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឯកភាពជាគោលការណ៍ធ្វើការធានាចំណាយនូវថវិកាបដិភាគរាជរដ្ឋាភិបាលជាទឹកប្រាក់ចំនួន ១.៦៤៧.៧00.000៛00 (មួយពាន់ប្រាំមួយរយសែសិបប្រាំពីរលានប្រាំពីររយពាន់រៀលគត់) សម្រាប់ការបោសសម្អាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ជំហានទី ២ នៅការដ្ឋានគម្រោងអភិវឌ្ឍន៍ធនធានទឹកព្រែកស្ទឹងកែវ ខេត្តកំពត។

សេចក្តីដូចបានជម្រាបខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងមានវិធានការ តាមការគួរ។

សូមឯកឧត្តមមេត្តាទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

ចម្លងជូន:

- មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកំលាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com